**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.០០៩........សហវ.......

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី២ ជំហានទី២ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) ដែលបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងដំណាក់កាលទី១ មាន ៣ជំហាន នៅរដ្ឋបាលកណ្ដាល សម្រាប់ក្រសួង ស្ថាប័ន ចំនួន២៣ និងមន្ទីរ អង្គភាពជំនាញ ចំនួន១៨ នៅរាជធានី ខេត្ត និងក្នុងដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ រួចមកហើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS បន្ថែម ទៅដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅដំណាក់កាលទី២ ជំហានទី២ សម្រាប់រដ្ឋបាលខណ្ឌ នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ និងនៅរដ្ឋបាលក្រុង ស្រុក ទូទាំងប្រទេស ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ តទៅ។

ដើម្បីឱ្យប្រព័ន្ធ NRMIS នេះដំណើរការបានរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មេត្តាជ្រាបដូចតទៅ៖

១.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានតម្រូវឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រើប្រាស់វិក្កយបត្រដែលមានលេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត)។

២.នៅដំណាក់កាលទី២ ជំហានទី២ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស នឹងត្រូវអនុវត្តការកត់ត្រា និងបង់ចំណូលតាមរយៈប្រព័ន្ធ NRMIS។

៣.បេឡាករ នៃធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ត្រូវបញ្ចូលលេខវិក្កយបត្រ ដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ទៅក្នុងបង្កាន់ដៃបង់ប្រាក់ (កន្លែងបរិយាយ/អត្ថន័យនៃការបង់ចំណូល) ដើម្បីផ្ដល់ភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់ប្រភពចំណូលជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៤.ក្នុងករណីចំណូលមិនមែនសារពើពន្ធទាំងឡាយណាពុំមានកំណត់លេខកូដទេនោះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំអាចបង់ចំណូលទាំងនោះបានឡើយ។

៥.ចំពោះចំណូលពីសេវាសាធារណៈ អតិថិជន ឬ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនអាចបង់សាច់ប្រាក់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ តិចជាង ឬ ច្រើនជាងទឹកប្រាក់នៅលើវិក្កយបត្រដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS នោះឡើយ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ការរៀបចំលេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត) នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ជាទម្រង់ ដូចខាងក្រោម÷

**ក. ចំណូលមុខងារផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

១. ចំណូលពីសេវារដ្ឋបាល (សេវារដ្ឋបាលផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ) ÷ **9XX-TT-9999**

២. ចំណូលក្រៅពីសេវារដ្ឋបាល (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ ចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត និងចំណូលពីពិន័យផ្សេងៗ) ÷ **9XX-PP-TT-9999**។

**ខ. ចំណូលដែលបានធ្វើប្រតិភូកម្ម ឬ ប្រគល់មុខងារ ពីក្រសួង ស្ថាប័ន របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

១. ចំណូលពីសេវាសាធារណៈ (សេវាដែលបានធ្វើប្រតិភូកម្ម ឬ ប្រគល់មុខងារ ពីក្រសួង ស្ថាប័ន) ÷ **9XX-MMM-TT-999**

២. ចំណូលក្រៅពីសេវាសាធារណៈ (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ ចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត និងចំណូលពីពិន័យផ្សេងៗ) ÷ **9XX-PP-MMM-TT-9999**។

❖ ***កំណត់សំគាល់*** (TT) ÷

ក. ផ្នែកកូដចំណូលពីសេវាសាធារណៈ លេខ 01

ខ. ផ្នែកកូដចំណូលពីទ្រព្យសម្បត្តិរដ្ឋ ÷ 02 ការជួល, 03 ភាគលាភ, 04 ចំណូលពីកាតព្វកិច្ចកាស៊ីណូ, 05 សម្បទាន, 06 ផលនេសាទ, 07 ចំណូលពីអាកាសចរស៊ីវិល, 08 ផ្សេងៗ, 09 ពិន័យ និង 10 ចំណូលពីកាតព្វកិច្ចឆ្នោត។

- XX : 01 សម្គាល់រាជធានី ខេត្ត, 02 សម្គាល់ក្រុង ស្រុក ខណ្ឌ និង 03 សម្គាល់ឃុំ សង្កាត់
- PP : កូដសម្គាល់ភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត
- MMM : កូដក្រសួង ស្ថាប័នដែលធ្វើប្រតិភូកម្ម ឬ ប្រគល់មុខងារ
- TT : ប្រភេទចំណូល
- 9999 : លេខរៀងចំណូល។

➢ <u>ឧទាហរណ៍ទី១</u> ÷ ចំណូលពីសេវារដ្ឋបាលផ្ទាល់ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 902<u>01</u>0001។

- 902 = សម្គាល់ចំណូលរបស់ក្រុង ស្រុក ខណ្ឌ
- 01 = សម្គាល់ប្រភេទចំណូលពីសេវាសាធារណៈ
- 0001 = សម្គាល់លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)។

*ខ្លឹមសារ÷ វិញ្ញាបនបត្របញ្ជាក់ការសិក្សា។*

➢ <u>ឧទាហរណ៍ទី២</u> ÷ ចំណូលពីសេវាសាធារណៈដែលបានធ្វើប្រតិភូកម្ម ឬ ផ្ទេរមុខងារ ពីក្រសួង ស្ថាប័ន ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 902<u>12001</u>0001។

- 902 = សម្គាល់ចំណូលរបស់ក្រុង ស្រុក ខណ្ឌ
- 120 = សម្គាល់ក្រសួងសុខាភិបាល
- 01 = សម្គាល់ប្រភេទចំណូលពីសេវាសាធារណៈ
- 0001 = សម្គាល់លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)។

*ខ្លឹមសារ÷ បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះមុន និងក្រោយសម្រាល (ស្នើសុំបើកថ្មី)។*

➢ <u>ឧទាហរណ៍ទី៣</u> ÷ ចំណូលពីទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ÷

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 902<u>1202</u>0001។

- 902 = សម្គាល់ចំណូលរបស់ក្រុង ស្រុក ខណ្ឌ
- 12 = សម្គាល់រាជធានីភ្នំពេញ
- 02 = សម្គាល់ប្រភេទចំណូលពីការជួល
- 0001 = សម្គាល់លេខរៀងចំណូល (លេខរៀងទី ១)។

*ខ្លឹមសារ៖ ជួលទីតាំង កខគ របស់រដ្ឋបាលខណ្ឌកំបូល។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មេត្តាជ្រាប និងផ្តល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**
- ធនាគារជាតិនៃកម្ពុជា
- ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ធនាគារ ឯកទេសវីង (ខេមបូឌា) លីមីធីត
- ធនាគារ វឌ្ឍនៈ
- ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
- គ្រឹះស្ថានហិរញ្ញវត្ថុដៃគូ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ